## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

## កំណត់ហេតុ

## កិច្ចប្រជុំ

## ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីពាន់ប្រាំពីរ ខែមិថុនា ថ្ងៃទី ដប់បួន វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំ A02 នៃទីស្តីការ គណៈរដ្ឋមន្ត្រី មានរៀបចំកិច្ចប្រជុំក្រោម អធិបតីភាពរបស់ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពិនិត្យ និងពិភាក្សាបន្តលើកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **សំ សុខផល** បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍មួយចំនួន និងមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនោះ។ ជាបន្ទាប់ឯកឧត្តម ប្រធានបានធ្វើសេចក្តីរាយការណ៍ ជូនអង្គប្រជុំអំពីការរីកចំរើន នៃការងាររបស់កំណែទម្រង់ច្បាប់ និងតុលាការ មុនពេលរៀបចំប្រជុំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ដែលនឹងត្រូវប្រារព្ធធ្វើនៅថ្ងៃទី ១៩-២០ ខែ មិថុនា ឆ្នាំ ២០០៧ ។ ឯកឧត្តមក៏បានស្វាគមន៍ផងដែរចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយ ដែលតែងតែយកចិត្តទុកដាក់ក្នុងការជួយជ្រោមជ្រែងធ្វើអោយសំរេចបាននូវសូចនាករតាមដានរួមពាក់ព័ន្ធដល់កំណែទម្រង់ច្បាប់ និងតុលាការ។

ឯកឧត្តមបានធ្វើការសង្ខេបអំពីស្ថានភាពច្បាប់ ជាមូលដ្ឋានដែលជាសូចនាករ ដែលនៅក្នុងនោះមានសេចក្តីព្រាងលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាដែលក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់បានពិនិត្យឡើងវិញចប់សព្វគ្រប់ ហើយរង់ចាំដាក់ជូនទៅកិច្ចប្រជុំអន្តរក្រសួងក្នុងពេលឆាប់ៗនេះ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**។

- ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តហើយកាលពី ថ្ងៃទី ០៧ ខែ ០៦ ឆ្នាំ ២០០៧ រង់ចាំដាក់ជូនទៅព្រឹទ្ធសភានៅពេលខាងមុខនេះដើម្បីអនុម័ត។

- ទាក់ទងទៅនឹងសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ឯកឧត្តមនឹងអញ្ជើញតំណាងអង្គភាពប្រឆាំងអំពើពុករលួយដើម្បីចូលរួមប្រជុំផងដែរ។ ឯកឧត្តមបានជម្រាបដល់អង្គប្រជុំថា ប្រសិនបើឯកឧត្តមអស់លោក លោកស្រីមានសំណួរពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយនេះ យើងអាចលើកជាសំណួរសួរទៅតំណាងអង្គភាពប្រឆាំងអំពើពុករលួយបាន។

-ឯកឧត្តមក៏បានជួបតំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីស្នើសុំឱ្យបញ្ចប់សេចក្តីព្រាងច្បាប់ចាត់តាំងតុលាការឱ្យឆាប់ផងដែរ។

- ទាក់ទងជាមួយស្ថានភាពនៃសេចក្តីព្រាងច្បាប់ផ្សេងៗទៀតគឺនៅដដែល។

លោក Pierre Espieu ជំនាញការច្បាប់បារាំងប្រចាំនៅក្រសួងយុត្តិធម៌ បានលើកឡើងថា សេចក្តីព្រាងច្បាប់ ទាំងឡាយដែលជាបន្ទុករបស់ក្រសួងយុត្តិធម៌ ត្រូវបានចេញផុតពីក្រសួងអស់ហើយ។ លោកមិនដឹងថាច្បាប់ណានៅទីណាទេ ហើយហេតុអ្វីបានជាច្បាប់ទាំងនោះមានការយឺតយ៉ាវនោះទេ ប៉ុន្តែសូមកុំបន្ទោសក្រសួងយុត្តិធម៌។

AusAid បានលើកឡើងថា វាជាការមួយល្អប្រសើរដែលយើងបានដឹងថា តើស្ថានភាពច្បាប់ទាំងនោះនៅ ទីណា? ហើយហេតុអ្វីបានជាជាប់គាំង? ប្រសិនបើយើងអាចដឹងស្ថានភាពទាំងនោះ ខាងម្ចាស់ជំនួយអាចរៀបចំធនធានក្នុងការជួយផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស ឬផ្នែកអ្វីៗផ្សេងទៀតបាន។

លោកស្រី Momoko Hotta (Assistant Resident Representative, JICA) ក៏បានឯកភាពទៅនឹងមតិខាងលើរបស់តំណាង AusAid ដែរ។ លោកស្រីបានមានប្រសាសន៍ថា អនុក្រុមទី2 អាចចូលរួមចំណែកក្នុងការតាមដាន និងគាំទ្រព្រោះនៅក្នុងអនុក្រុមទី២នេះ យើងបានរៀបចំជាបញ្ជីច្បាប់ និងលិខិតបទដ្ឋានផ្សេងៗផងដែរ។

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា នៅក្នុងរបាយការណ៍របស់ឯកឧត្តមបានបញ្ជាក់អំពីសេចក្តីត្រូវការរបស់ក្រសួងយុត្តិធម៌ក្នុងការស្វែងរកដៃគូអភិវឌ្ឍន៍ផ្សេងៗ។ តាមពិតទៅ យើងបានដឹងរួចហើយអំពីស្ថានភាព នៃច្បាប់ទាំងអស់នោះថាតើច្បាប់ទាំងនោះស្ថិតនៅទីណា? យើងបានដឹងរួចហើយថាច្បាប់ដែលទាក់ទងនឹងវិស័យតុលាការ ភាគច្រើនស្ថិតនៅក្រោមការសម្របសម្រួលរបស់ក្រសួងយុត្តិធម៌ ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច។ ឯកឧត្តមបានសុំឱ្យអនុក្រុមទាំងអស់ធ្វើការតាមដានលើសេចក្តីព្រាងច្បាប់ដែលពាក់ព័ន្ធនឹងសូចនាករថ្មី ហើយយើងត្រូវធ្វើបញ្ចប់សេចក្តីព្រាង និងធ្វើការអនុម័តច្បាប់ ដែលនៅសេសសល់ជាមួយច្បាប់ទាំងប្រាំបី។

-ទាក់ទងនឹងទិសដៅជាយុទ្ធសាស្ត្រទី២ និយាយអំពីដំណើរការនៃការធ្វើច្បាប់ គួរតែស្វែងរកជំនួយបច្ចេកទេស ពីខាងក្រៅសម្រាប់ការកសាងសមត្ថភាពជាដើម។

-ទាក់ទងនឹងទិសដៅជាយុទ្ធសាស្ត្រទី៤ និងយុទ្ធសាស្រទី៧ ពាក់ព័ន្ធដល់ការបណ្តុះបណ្តាល និងការជ្រើសរើសប្រកបដោយតម្លាភាពនូវមន្ត្រីបម្រើផ្នែកតុលាការ ឯកឧត្តមក៏បានស្នើជំនួយពីខាងក្រៅ ផងដែរ។

លោកស្រី Kathryn Elliott តំណាងអង្គការ AusAid បានរាយការណ៍ជូនអង្គប្រជុំអំពីការពេញចិត្តនៃសហគមន៍អ្នកផ្ដល់ជំនួយចំពោះដំណើរការរៀបចំសូចនាករតាមដានរួមនេះ ដោយបានពិនិត្យរួមគ្នាមុននឹងដាក់ជូនទៅអគ្គលេខាធិការដ្ឋាន វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងបានលើកឡើងអំពីការរៀបចំគម្រោងពង្រីកបន្ថែមតុលាការគំរូ ដោយបានជម្រាបជូនអង្គប្រជុំថា ក្រុមការងារជាន់ខ្ពស់នេះបានជួបប្រជុំគ្នាសម្រាប់គម្រោងកាលពីពីរ ឬបីសប្តាហ៍កន្លងទៅនេះ។ ក្រុមការងារជាន់ខ្ពស់នេះបានឯកភាពបង្កើតតុលាការចំនួនបីបន្ថែមទៀតគឺ តុលាការក្រុងភ្នំពេញ តុលាការខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ។ បូករួមទាំងតុលាការគំរូខេត្តកណ្តាល ដែលមានស្រាប់សរុបទាំងអស់មានតុលាការគំរូចំនួនបួន។

ជាដំបូងក្រុមការងារជាន់ខ្ពស់ជាអ្នកសម្រេចគោលនយោបាយ បន្ទាប់មកមានក្រុមការងារបច្ចេកទេសដែលជា អ្នករៀបចំកិច្ចការបច្ចេកទេស ហើយបន្ទាប់មកទៀតមាន ក្រុមការងារមួយដែលធ្វើការនៅតុលាការគំរូដែលបានជ្រើសរើស។

ក្រុមការងារជាន់ខ្ពស់ដែលមានសមាសភាពមកពីក្រសួងយុត្តិធម៌ តុលាការក្រុងភ្នំពេញ សាលាឧទ្ធរណ៍ តុលាការកំពូល និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតំណាងដៃគូអភិវឌ្ឍន៍ដែលជួយគាំទ្រគម្រោងនេះមាន AusAid, Danida, JICA, France, UNDP, World Bank។ ឯកឧត្តមបានជម្រាបអង្គប្រជុំថា បើសិនជាម្ចាស់ជំនួយ ឬក៏ដៃគូអភិវឌ្ឍន៍ដ៏ទៃទៀតចាប់អារម្មណ៍ក៏អាចចូលរួមបានដែរ។

សម្រាប់ក្រុមការងារបច្ចេកទេសគឺក្រុមការងារជាន់ខ្ពស់ បានសម្រេចយកតែសមាជិកស្ថាប័នពាក់ព័ន្ធជាតិតែប៉ុណ្ណោះ។ រហូតមកដល់ពេលនេះក្រុមការងារបច្ចេកទេសនេះមានតំណាងមកពី ក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ និងតុលាការក្រុងភ្នំពេញ។

ឯកឧត្តមប្រធានអង្គភាពគ្រប់គ្រងគម្រោង បានលើកឡើងផងដែរអំពីការរង់ចាំការតែងតាំងតំណាងពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីដំណើរការបន្ត។

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថាបើសិនជាម្ចាស់ជំនួយ ឬដៃគូអភិវឌ្ឍន៍ចង់ជួយឯកឧត្តមសូមស្វាគម៍ជានិច្ច។

លោកស្រី Momoko Hotta ជាតំណាងអនុក្រុមទី២ បានបង្ហាញពីស្ថានភាពជឿនលឿន នៃការងារអនុក្រុមទី២ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ទាក់ទងនឹងបញ្ជីច្បាប់លោកស្រីមានប្រសាសន៍ថា នឹងដាក់ជូនទៅស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីបំពេញនូវច្បាប់ទាំងឡាយណា ដែលបានធ្វើរួចហើយ ហើយបញ្ជូនមក JICA ឬក៏បញ្ជូនមកអង្គភាពគ្រប់គ្រងគម្រោងក៏បាន។ លោកស្រីបានបញ្ជាក់ថាការធ្វើបញ្ជីច្បាប់នេះមានសារៈសំខាន់ណាស់ សម្រាប់ក្រុមការងារធ្វើការតាមដាននិងដឹងថា តើក្រសួងណាធ្វើច្បាប់អ្វី និងដល់ណាហើយ?។

ទាក់ទងនឹងការធ្វើច្បាប់គម្រូវឱ្យ WTO លោកស្រីបានស្នើសុំឱ្យតំណាងក្រសួងពាណិជ្ជកម្មធ្វើការបង្ហាញ និងសុំឱ្យតំណាងខាងក្រសួងនេះចូលរួមប្រជុំជាមួយអនុក្រុមទី២ ដើម្បីឱ្យមានការស៊ីសង្វាក់គ្នា។

ទាក់ទងនឹងការដាក់បញ្ចូលទិសដៅជាយុទ្ធសាស្ត្រទី៣ ចូលក្នុងអនុក្រុមទី២ លោកស្រីបានបញ្ជាក់ថា ទិសដៅនេះមានបួនគម្រោង ៖

គម្រោងទី១-សន្ធានុក្រមបីភាសា

គម្រោងទី២-រាជកិច្ច

គម្រោងទី៣-ការផ្សព្វផ្សាយសេចក្ដីសម្រេចរបស់តុលាការ

គម្រោងទី៤-ការទទួលព័ត៌មាន(ការិយាល័យទទួលព័ត៌មាននៅតុលាការ)

លោកស្រីសំណូមពរឱ្យដាក់គម្រោងទី៤(ការិយាល័យទទួលព័ត៌មាន) បញ្ចូលទៅក្នុងអនុក្រុមទី៤ ព្រោះមានការទាក់ទងគ្នាច្រើន។

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា ទាក់ទងនឹងភាពស៊ីសង្វាក់គ្នា នៃច្បាប់កាលប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានសម្រេចឱ្យទៅឯកឧត្តម **ស៊ុំ ម៉ានិត** រៀបចំជាកំណត់បង្ហាញ។ ក្នុងរឿងនេះឯកឧត្តម **ស៊ុំ ម៉ានិត** បានរៀបចំជាកំណត់បង្ហាញខ្លីៗ និយាយអំពីភាពមិនស្របគ្នា ហើយបានដាក់ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីពិគ្រោះយោបល់ជាមួយក្រសួងពាណិជ្ជកម្មផងដែរ។

លោក Pierre Espieu បានលើកឡើងថា ទាក់ទងនឹងការងារអនុក្រុមទី២ ចំណុចខ្លះហាក់ដូចជាក្រុមនេះមិនទាន់យល់ច្បាស់នៅឡើយនៅក្នុងនោះមាន ៖

-ទាក់ទងនឹងនីតិវិធីនៃច្បាប់ និងបញ្ហាការតាមដាន

-និយាយពីភាពមិនស៊ីសង្វាក់គ្នានៃច្បាប់ជាដើម លោកបានមានមតិថា ច្បាប់ជាមូលដ្ឋាននោះ មានន័យថា បើយើងកំណត់ច្បាប់អ្វីមួយជាមូលដ្ឋាន គឺច្បាប់ទាំងអស់ត្រូវតែស្របជាមួយច្បាប់ជាមូលដ្ឋាននោះដែរ។

លោកស្រី Momoko Hotta បានមានប្រសាសន៍ថា ជាការល្អហើយដែលឯកឧត្តមប្រធានក្រុមការងារបច្ចេកទេសចម្រុះ បានពិភាក្សាជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី អំពីភាពមិនស៊ីសង្វាក់គ្នា នៃច្បាប់មួយចំនួននោះ។ ខាងជំនាញការច្បាប់របស់ JICA និង FRANCE នឹងរៀបចំជាពង្រាងកំណត់ត្រាមួយ ដើម្បីធ្វើជាឯកសារផងដែរ។

លោកស្រី Ana Janet Sunga, UNICEF បានឯកភាពជាមួយ JICA និង FRANCE ដែលបានលើកឡើងពីច្បាប់ផ្សេងៗទៀតឱ្យស្របគ្នាទៅនឹងច្បាប់ជាមូលដ្ឋាននោះ។ ទាក់ទងនឹងច្បាប់អនីតិជន លោកស្រីមានមតិយោបល់ថា គឺយើងធ្វើយ៉ាងណាឱ្យមានលក្ខណៈទាំងពីរយ៉ាង។

លោក **លី តាយសេង** បានចូលរួមយោបល់ទៅលើការមិនស៊ីសង្វាក់គ្នានេះ ដោយឯកភាពជាមួយមិតតំណាង UNICEF និងបានឯកភាពទៅនឹងការលើកឡើងរបស់លោក Pierre Espieu ផងដែរ។ ចំពោះទស្សនៈលោកផ្ទាល់អំពីភាពមិនស្របគ្នានៃច្បាប់ផ្សេងៗ ជាបញ្ហាមួយដែលត្រូវតែដោះស្រាយ ប៉ុន្តែដូចយើងដឹងស្រាប់ហើយការធ្វើច្បាប់នីមួយៗមិនមែនជាការងាយស្រួលទេ ទាំងច្បាប់ពិសេស ទាំងច្បាប់ជាមូលដ្ឋានសុទ្ធសឹងជារឿងបច្ចេកទេស និងមានលក្ខណៈស្មុគ្រស្មាញ ហើយលោកតែងមានការកោតសរសើរដល់ជំនាញ

ការឯកទេសផ្សេងៗ ដែលបានចូលរួមធ្វើច្បាប់សម្រាប់កម្ពុជា ទាំងជំនាញការបារាំង ជំនាញការជប៉ុន, និង ជំនាញការផ្សេងៗទៀតដូចជាអាមេរិកាំងជាដើម។ ក្នុងពេលជាមួយគ្នានោះដែរ លោកបានមានមតិយោបល់ថា ការធ្វើច្បាប់គឺមិនមែនធ្វើស្របទៅតាមឆន្ទៈ ដែលជំនាញការចង់បាននោះទេ គឺយើងគួរគិតដល់ឆន្ទៈរបស់ ប្រជាពលរដ្ឋ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលរបស់កម្ពុជាផងដែរ។

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា ឯកឧត្តម និងឯកឧត្តម **ស៊ុយ ម៉ុងលាង** នឹងលើកយកបញ្ហាភាពមិនស៊ីសង្វាក់គ្នាច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានៃច្បាប់ទាំងអស់នេះ ទៅជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីសុំជាមតិយោបល់។ ហើយលទ្ធផលជំនួបពិភាក្សាយ៉ាងណានោះ ឯកឧត្តមនឹងជម្រាបជូននៅពេលមានកិច្ចប្រជុំការងារបច្ចេកទេសចម្រុះលើកក្រោយទៀត។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានមានប្រសាសន៍ថា ច្បាប់ជាមូលដ្ឋានបានអនុម័តរួចហើយ ហើយ ច្បាប់ផ្សេងៗទៀតត្រូវតែស្របនឹងច្បាប់ជាមូលដ្ឋាននេះ។ ឯកឧត្តមបានសំដែង នូវការពេញចិត្តចំពោះអនុក្រុម ទី២ ដែលមានការរីកចំរើនយ៉ាងល្អបែបនេះ។

ទាក់ទងនឹងការដាក់បញ្ចូលទិសដៅជាយុទ្ធសាស្ត្រទី៣ចូលក្នុងអនុក្រុមទី២ ឯកឧត្តមមានយោបល់ថា យើងអាចដាក់បញ្ចូលគ្នាបានព្រោះក្នុងនោះ គម្រោងមួយចំនួនដូចជាគម្រោងសន្ទានុក្រមបីភាសា យើងមាន គណៈកម្មាការជាតិមួយ ដែលមានឯកឧត្តម **សំ សុខផល** ជាប្រធានជាអ្នកសម្រេចជាចុងក្រោយលើពាក្យ ច្បាប់ ដែលត្រូវយកមកប្រើ។ ដូចនេះអនុក្រុមពុំមានការងារតាមដានពិនិត្យឡើងវិញទេ។

ជាចុងក្រោយ ឯកឧត្តមបានលើកឡើងពីលទ្ធផលសំខាន់ នៃកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ កាលពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧ កន្លងទៅថ្មីៗនេះ។ ឯកឧត្តមបានបញ្ជាក់ជូន អង្គប្រជុំថា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បានសម្រេច និងដោះស្រាយបញ្ហាមួយចំនួន ដែលទាក់ទងទៅនឹងការអនុវត្តផែនការសកម្មភាព នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័តុលាការ ដែល មានការយឺតយ៉ាវព្រមទាំងលើកឡើង នូវដំណោះស្រាយបញ្ហាមួយចំនួនសំខាន់ៗដូចខាងក្រោមនេះ ៖

- ទាក់ទងនឹងការខ្វះខាតចៅក្រម និងព្រះរាជអាជ្ញា ក្រុមប្រឹក្សាបានសម្រេចថា នឹងរើស សិស្សចៅក្រម ឱ្យបានច្រើនជាអតិបរមាតាមលទ្ធភាពដែលសាលាភូមិន្ទចៅក្រមអាចធ្វើ ទៅបាន។
- ទាក់ទងនឹងបញ្ហាការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ ក្រុមប្រឹក្សាបានសម្រេចបង្កើត យន្តការឱ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន។
- បច្ចុប្បន្នការបោះពុម្ពផ្សព្វផ្សាយសេចក្តីសម្រេចតុលាការ និងរាជកិច្ចត្រូវធ្វើឡើងដោយ នាយកដ្ឋានរាជកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី ឥឡូវនេះខាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងធ្វើការបោះពុម្ពដោយខ្លួនឯងវិញ។
- នឹងរៀបចំការជ្រើសរើសសិស្សអាជ្ញាសាលាក្នុងពេលឆាប់ៗខាងមុខនេះ ដោយមានជំនួយ មកពីបរទេស។
- ពង្រឹងបន្ថែមដំណើរការនៃការប្រាស្រ័យទាក់ទងគ្នា ធ្វើការផ្សព្វផ្សាយការងារដែលយើង បានធ្វើរួចមកហើយ។

- ទាក់ទងនឹងបញ្ហាប្រឆាំងអំពើពុករលួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានលើកឡើងផង ដែរថា ប្រសិនបើនរណាម្នាក់ចង់ដឹងពីវិធានការប្រឆាំងអំពើពុករលួយ អាចអញ្ជើញមក ទីស្តីការគណៈរដ្ឋ មន្ត្រី យើងនឹងពន្យល់ប្រាប់អំពីវិធានការនោះ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងប្រាំគត់ល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង** **អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** **សេង វ៉ាន់ដា ស៊ុន សិរីវុធ**

**បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា**
**នាថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧**

០១-ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ
០២-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៣-ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៤-លោក ឆៃ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ ក.ក.ច.ន.យ
០៥-លោក ឆុង ហួត ប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
០៦-លោក គង់ ផល្លៈ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
០៧-លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណ័សារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
០៨-កញ្ញា ផាន់ ពីសីនលក្ខណ៍ មន្ត្រី ក.ក.ច.ន.យ
០៩-លោក កួយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
១០-លោកស្រី ឈូក សារ៉ុម មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១១-លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១២-លោក ជ សៀកវ៉េង CCJAPIII

១៣-លោកជំទាវ ចាន់ សុទ្ធាវី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
១៤-លោកជំទាវ សម មូនីកា អគ្គនាយករងក្រសួងកិច្ចការនារី
១៥- Khoun Samnang, Deputy Director Legal Department ( Ministry of Commerce )
១៦- Kheang Seng, AGU
១៧- Ms.Ana Janet Sanga, UNICEF
១៨- Kake Elliott, AusAid
១៩- Ben Schultz, CCJAPIII
២០- Ly TaySeng, General Secretary of Bar Association
២១- Mr. Ros Chhay ( Senior Program Officer ) Australian Embassy
២២- Momoko Hotta ( Assistant Resident Representative, JICA )
២៣- Mr. Real Real Sophen, Ministry of Interror
២៤- Seng Rethy Rethy, Lawyer
២៥- Kumi Mochizuki ( Third Secretary ) Embassy of Japan in Phnom Penh
២៦- Mr. Pierre Espieu, Chef de project, Appui à L' Etat de Droit, France
២៧- Kong Rady, UNDP
២៨- Nuon Sothimon, Anti-Corruption Unit
២៩- Song Vannsin, EU
៣០-Kamiki Atsushi

៣០ Kamiki Atsushi